# *សេចក្តីប្រកាសពត៌មាន*

សម្រាប់ការផ្សាយជាបន្ទាន់
ថ្ងៃចន្ទទី៣០ខែមិថុនាឆ្នាំ២០១៤

## **របាយការណ៍សំយោគលើកទី៣១របស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារកឃើញពីការកើនឡើងនិងការថយចុះនៃលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេរ**

ប្រទេសកម្ពុជា-ភ្នំពេញ ភាពអនុលោមទៅតាមលក្ខខណ្ឌច្បាប់នៃប្រទេសកម្ពុជាបង្ហាញឱ្យឃើញពីការកើនឡើង និង ការថយចុះ នៃលក្ខខណ្ឌសំខាន់ៗមួយចំនួយដូចជាសុវត្ថិភាពអគ្គីភ័យ ពលកម្មកុមារ និង សុខភាពនិងសុវត្ថិភាពរបស់កម្មករនិយោជិតយោងតាមរបាយការណ៍សំយោគថ្មីបំផុតរបស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ។ របាយការណ៍សំយោគលើកទី៣១ឆ្លុះបញ្ចាំងពីទិន្នន័យនៃការអនុលោមពីរបាយការណ៍ការត្រួតពិនិត្យពីថ្ងៃទី១ខែឧសភាឆ្នាំ២០១៣ ដល់ថ្ងៃទី៣០ខែមេសាឆ្នាំ២០១៤។ អំឡុងពេល១២ខែនេះ គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាបានបង្កើតរបាយការណ៍រោងចក្រកាត់ដេរចំនួន៣៦២ និង រោងចក្រស្បែកជើងចំនួន៩។

ស្របពេលដែលរបាយការណ៍នេះបង្ហាញពីការកែលំអមួយចំនួន ពាក់ព័ន្ធជាមួយនឹងការផ្តល់ប្រាក់ ឈ្នួល និងអត្ថប្រយោជន៍នានាបានត្រឹមត្រូវ ព្រមទាំងកម្រិតខ្ពស់នៃភាពអនុលោមតាមច្បាប់ចំពោះសិទ្ធិជាមូលដ្ឋាន ភាពមិនអនុលោមតាមច្បាប់នៅក្នុងផ្នែកនានា ដែលពាក់ព័ន្ធជាមួយនឹងបញ្ហាសន្លប់ នៅក្នុងឧស្សាហាកម្ម និងបញ្ហាសុខភាពនិងសុវត្ថិភាពរបស់កម្មករនិយោជិត នៅតែជាបញ្ហាសំខាន់។

លោកស្រី ជាលតាក់កឺ ប្រធានប្រឹក្សាបច្ចេកទេសនៃគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាបានថ្លែងថា ៖″របាយការណ៍នេះបានថតយកការកើនឡើងនិងការថយចុះនៃឧស្សាហកម្មកាត់ដេរក្នុងរយៈពេលមួយឆ្នាំ រួមមានការកើនឡើងយ៉ាងខ្លាំងនៃឧស្សាហកម្ម និង ការធ្វើកូដកម្មយ៉ាងសម្បើមលើបញ្ហាប្រាក់ឈ្នួល ព្រមទាំងការកែលំអគួរឱ្យកត់ សម្គាល់ក្នុងលក្ខខណ្ឌការងារ។″

លោកស្រីបន្តថា៖ ″ថ្មីៗនេះ ពួកយើងបានឃើញការផ្លាស់ប្តូរប្រកបដោយភាពលើកទឹកចិត្តមួយចំនួននៅក្នុងរោងចក្រ បន្ទាប់ពីការត្រលប់ទៅកាន់ការចេញផ្សាយរបាយការណ៍តម្លាភាពរបស់គំរោង។ របាយការណ៍តម្លាភាពលើកទីពីររបស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នឹងត្រូវបានចេញផ្សាយនៅដើមខែកក្កដាខាងមុខនេះ។″

របាយការណ៍នេះក៏បានកត់សម្គាល់ផងដែរថា ក្នុងចំណោមកូដកម្មចំនួន ១០៨ករណី ដែលកើតមានឡើង នៅក្នុងរយៈពេលនៃការរាយការណ៍នេះ ដែលកូដកម្មទាំង ១០០% មិនបាន អនុលោមទៅតាមគ្រប់លក្ខខណ្ឌតម្រូវដោយច្បាប់

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org

ទាំងអស់ ហើយចំនួននៃកូដកម្មបានកើនឡើង៣ដងតាំងពីឆ្នាំ២០១១។

នៅក្នុងផ្នែកសេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់ របស់របាយការណ៍នេះ រោងចក្រកាន់តែប្រសើរនៅ កម្ពុជាលើកឡើងពីវិធានការនានា ដែលអ្នកពាក់ព័ន្ធនានារបស់ឧស្សាហកម្មនេះ ដូចជា រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា អ្នកបញ្ជាទិញអន្តរជាតិ និង សហជីព ដើម្បីជួយធានាឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។ ផ្នែកនេះក៏រៀបរាប់ពីសកម្មភាព ដែលរោងចក្រកាន់ តែប្រសើរនៅកម្ពុជាបានអនុវត្ត ឬនឹងអនុវត្ត ដើម្បីជួយជម្រុញឱ្យមានភាពអនុលោមតាមច្បាប់ផងដែរ។

ដើម្បីទាញយករបាយការណ៍សំយោគលើកទី ៣១ ស្តីពីលក្ខខណ្ឌការងារ នៅក្នុងវិស័យកាត់ដេរ កម្ពុជា ជាភាសាខ្មែរ ឬអង់គ្លេស សូមចូលមើលគេហទំព័រ www.betterfactories.org ។

សម្រាប់ពត៌មានបន្ថែម សូមទាក់ទង ៖
លោក គាំ ទីវា
មន្ត្រីទំនាក់ទំនងពត៌មាន
អ៊ីមេល ៖ tivea@ilo.org
លេខទូរស័ព្ទ ៖ (៨៥៥) ២៣ ២១២ ៨៤៧